ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

លេខ : ១១៩/១៧ .........រ.ប.ក

# របាយការណ៍បូកសរុបលទ្ធផលការងារខែ កក្កដា ឆ្នាំ២០១៧ និងទិសដៅអនុវត្តបន្ត របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

## I. ស្ថានភាពទូទៅ

នៅក្នុងខែកក្កដា ឆ្នាំ២០១៧នេះ អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ បានខិតខំបំពេញការងារយ៉ាងមមាញឹកពាក់ព័ន្ធនឹងបញ្ហានៃការអនុវត្តច្បាប់អន្តោប្រវេសន៍ ៨ចំណុចក្នុងការគ្រប់គ្រងពលករបរទេស របស់អាជ្ញាធរថៃ ដោយបានចាប់ពលករខ្មែរខុសច្បាប់បញ្ជូនត្រឡប់មកកម្ពុជាវិញរាប់ពាន់នាក់ នៅតាមបណ្តាច្រកទ្វារព្រំដែនអន្តរជាតិ ។ ពាក់ព័ន្ធនឹងបញ្ហានេះ អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ បានបើកកិច្ចប្រជុំជាច្រើនលើក ដើម្បីសិក្សា និងពិភាក្សាស្វែងរកវិធានការដោះស្រាយ និងគ្រប់គ្រងជាបន្ទាន់ មិនតែប៉ុណ្ណោះ **ឯកឧត្តមអគ្គលេខាធិការគ.ជ.ប.ជ ឯកឧត្តម-លោកជំទាវអគ្គលេខាធិការរង និងមន្ត្រីមួយចំនួន** បានចូលរួមក្នុងគណៈប្រតិភូក្រុមការងារអន្តរក្រសួង ដឹកនាំដោយ **លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ** ចុះបំពេញបេសកកម្មការងារទៅកាន់ខេត្តជាប់ព្រំដែនប្រទេសថៃចំនួន០៣គឺ ខេត្តប៉ៃលិន បាត់ដំបង និងខេត្តបន្ទាយមានជ័យ ដើម្បីសិក្សាអំពីស្ថានភាព និងស្វែងរកដំណោះស្រាយសមស្របពាក់ព័ន្ធចំពោះបញ្ហាបញ្ជូនពលករត្រឡប់នេះ ហើយជាលទ្ធផលបេសកកម្មការងារនេះបានប្រព្រឹត្តទៅដោយមានកិច្ចសហការល្អពីអាជ្ញាធរមូលដ្ឋាន សមត្ថកិច្ច និងមន្ត្រីតំណាងមកពីមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ និងទទួលបានលទ្ធផលគួរឲ្យកត់សម្គាល់ ។ ក្រៅពីការងារខាងលើនេះ អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ បានរៀបចំកិច្ចប្រជុំអន្តរក្រសួងសំខាន់ៗចំនួនពីរ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** ទី១-កិច្ចប្រជុំស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ប្រចាំឆមាសទី១ ឆ្នាំ២០១៧ និងទី២-កិច្ចប្រជុំផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីសម្រាប់ការស្នើសុំទារកករណីពពោះជំនួសដើម្បីយកទៅចិញ្ចឹមនៅក្រៅប្រទេស ។ សម្រាប់ការងារបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្នុងខែនេះអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ បើកបានចំនួន ០១វគ្គនៅខេត្តកំពង់ស្ពឺ ។ សម្រាប់ការងារប្រចាំថ្ងៃ អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ នៅតែបន្តទំនាក់ទំនង និងសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា ក្នុងការជំរុញការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែមានប្រសិទ្ធភាព ។

## II. សកម្មភាព និង លទ្ធផលការងារ

### ក. លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

- ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៧ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការរៀបចំចុះតាមដានការអនុវត្តវិធានការ និងដំណោះស្រាយរបស់អាជ្ញាធរក្នុងការគ្រប់គ្រងលំហូរពលករចេញ-ចូលតាមខ្សែបន្ទាត់ព្រំដែន

កម្ពុជា-ថៃ តាមសេចក្តីជូនដំណឹងលេខ ១០២៥ ស.ជ.ណ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន ។

- ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ បានដឹកនាំកិច្ចប្រជុំជាមួយតំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអង្គការ IJM ស្តីពីបញ្ហានៃការបញ្ជូនពលករខ្មែរខុសច្បាប់ត្រឡប់មកពីប្រទេសថៃវិញយ៉ាងច្រើន នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន ។
- ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ បានអញ្ជើញជាវាគ្មិនកិត្តិយស ធ្វើបទបង្ហាញអំពីបទពិសោធន៍នៃការដឹកនាំស្ថាប័នរដ្ឋ នៅក្នុងសិក្ខាសាលាស្តីពីការពង្រឹងតួនាទីស្ត្រីក្នុងវិស័យនយោបាយ ក្រោមប្រធានបទស្ត្រី និងការដឹកនាំ នៅទីស្តីការក្រសួងបរិស្ថាន ។
- ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរក្រសួង ស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ប្រចាំឆមាសទី១ ឆ្នាំ២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ មានសមាសភាពចូលរួមចំនួន ៥៩នាក់ (ស្រី ១៩នាក់) ។
- ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង និងថ្នាក់ក្រោមជាតិ ស្តីពីផែនការសកម្មភាពជាតិ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់អនុវត្តបន្តឆ្នាំ២០១៧-២០១៨ នៅទីស្តីការក្រសួងមហាផ្ទៃ មានសមាសភាពចូលរួមចំនួន ៨៧នាក់ (ស្រី ៤៩នាក់) ។
- ថ្ងៃទី ១៥-១៧ ខែកក្កដា ឆ្នាំ២០១៧ បានដឹកនាំគណៈប្រតិភូបំពេញបេសកកម្មការងារអន្តរក្រសួងទៅខេត្តជាប់ព្រំដែនកម្ពុជា-ថៃចំនួន០៣ ប៉ៃលិន បាត់ដំបង និងបន្ទាយមានជ័យ ដើម្បីសិក្សាអំពីស្ថានភាពនៃការបញ្ជូនពលករត្រឡប់មកពីប្រទេសថៃ និងការស្វែងរកដំណោះស្រាយសមស្របសម្រាប់ពលករឆ្លងកាត់ព្រំដែន ក្រោមការសម្របសម្រួលពីអាជ្ញាធរ និងសមត្ថកិច្ចខេត្តជាប់ព្រំដែន ដែលសមាសភាពគណៈប្រតិភូមានចំនួន ១០នាក់ (ស្រី ០៥នាក់) ។
- ថ្ងៃទី ២១-២២ ខែកក្កដា ឆ្នាំ២០១៧ បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាគោលនយោបាយ ស្តីពីតួនាទីនៃប្រទេសដើម (Policy Dialogue Meeting on the Role of Countries of Origin) នៅទីក្រុងរ៉ង់ហ្គូន ប្រទេសភូមា ។
- ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧ បានអញ្ជើញជាគណៈអធិបតី ក្នុងសិក្ខាសាលាស្តីពីកិច្ចសហការដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម នៅខេត្តកោះកុង ។
- ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ រសៀល បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរក្រសួង ផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីសម្រាប់ការស្នើសុំទារក ករណីពពោះជំនួសដើម្បីយកទៅចិញ្ចឹមនៅក្រៅប្រទេស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងស្ថានទូតបរទេសប្រចាំព្រះរាជាណាចក្រកម្ពុជា សរុបចំនួន ៦១នាក់ (ស្រី ២២នាក់) ។

- ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ បានអញ្ជើញជាអធិបតី និងជាវាគ្មិន ក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តកំពង់ស្ពឺ មានសិក្ខាកាមចូលរួមចំនួន ៦២នាក់ (ស្រី ១៣នាក់) ។
- ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ បានអញ្ជើញជួបប្រជុំពិភាក្សាជាមួយតំណាងអង្គការការីតាស់កម្ពុជា ស្តីពីទិវាជាតិអន្តរសាសនានៅកម្ពុជា នៅសាលាប្រជុំអគ្គលេខាធិការដ្ឋាន មានសមាសភាពចូលរួមចំនួន ៨នាក់ (ស្រី ២នាក់) ។ និងបានអញ្ជើញជួបពិភាក្សាជាមួយតំណាងតុលាការរាជធានីភ្នំពេញ អំពីនីតិវិធីនៃការសុំយកកូនចេញទៅក្រៅប្រទេស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន ។
- ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ បានអញ្ជើញចូលរួមប្រជុំផ្ទៃក្នុង ពិនិត្យរៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៧-២០១៨ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានសមាសភាពចូលរួមចំនួន ១២នាក់ (ស្រី ២នាក់) ។

**ខ. ឯកឧត្តម ឧត្តមសេនីយ៍ឯក ថោង សំអាត អគ្គលេខាធិការ**

- ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៧ បានអញ្ជើញចូលរួមកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការរៀបចំចុះតាមដានការអនុវត្តវិធានការ និងដំណោះស្រាយរបស់អាជ្ញាធរក្នុងការគ្រប់គ្រងលំហូរពលករចេញ-ចូលតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ។
- ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ បានអញ្ជើញចូលរួមប្រជុំជាមួយតំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអង្គការ IJM ស្តីពីបញ្ហានៃការបញ្ជូនពលករខ្មែរខុសច្បាប់ត្រឡប់មកពីប្រទេសថៃវិញយ៉ាងច្រើន ។
- ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរក្រសួង ស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ប្រចាំឆមាសទី១ ឆ្នាំ២០១៧ នៅទីស្តីការក្រសួងមហាផ្ទៃ ។
- ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរក្រសួង ស្តីពីផែនការសកម្មភាពជាតិរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់អនុវត្តបន្តឆ្នាំ២០១៧-២០១៨ នៅទីស្តីការក្រសួងមហាផ្ទៃ ។
- ថ្ងៃទី ១៥-១៧ ខែកក្កដា ឆ្នាំ២០១៧ បានអញ្ជើញជាប្រតិភូចុះបំពេញបេសកកម្មការងារអន្តរក្រសួងទៅខេត្តជាប់ព្រំដែនកម្ពុជា-ថៃចំនួន០៣ ប៉ៃលិន បាត់ដំបង និងបន្ទាយមានជ័យ ដើម្បីសិក្សាអំពីស្ថានភាពនៃការបញ្ជូនពលករត្រឡប់មកពីប្រទេសថៃ និងការស្វែងរកដំណោះស្រាយសមស្របសម្រាប់ពលករឆ្លងកាត់ព្រំដែន ក្រោមការសម្របសម្រួលពីអាជ្ញាធរ និងសមត្ថកិច្ចខេត្តជាប់ព្រំដែន ។
- ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ រសៀល បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរក្រសួង ផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីសម្រាប់ការស្នើសុំទារក ករណីពពោះជំនួសដើម្បីយកទៅចិញ្ចឹមនៅក្រៅប្រទេស នៅទីស្តីការក្រសួងមហាផ្ទៃ ។
- ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ បានអញ្ជើញចូលរួមប្រជុំពិភាក្សាជាមួយតំណាងអង្គការការីតាស់កម្ពុជា ស្តីពីទិវាជាតិអន្តរសាសនានៅកម្ពុជា ។ និងបានអញ្ជើញចូលរួមជួបពិភាក្សាជាមួយតំណាងតុលាការរាជធានីភ្នំពេញ អំពីនីតិវិធីនៃការសុំយកកូនចេញទៅក្រៅប្រទេស ។
- ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ បានអញ្ជើញចូលរួមប្រជុំផ្ទៃក្នុង ពិនិត្យរៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៧-២០១៨ ។

- បានដឹកនាំត្រួតពិនិត្យវត្តមាន វិន័យ និងសណ្តាប់ធ្នាប់របស់មន្ត្រីនគរបាល និងមន្ត្រីស៊ីវិលនៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ នៅរៀងរាល់ព្រឹកថ្ងៃច័ន្ទ នៃសប្តាហ៍នីមួយៗ ។

## គ. អគ្គលេខាធិការដ្ឋាន

- ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ លោកឧត្តមសេនីយ៍ទោ គង់ ពុទ្ធី ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប បានដឹកនាំកិច្ចប្រជុំលេខាធិការដ្ឋាន ដើម្បីប្រកាសសេចក្តីសម្រេចអំពីតួនាទីភារកិច្ចរបស់ប្រធាន-អនុប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប និងពង្រឹងការងារតាមការិយាល័យ ។

### ១. លេខាធិការដ្ឋាន

- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ(៣០ច្បាប់) លិខិតចូល(១៣ច្បាប់)
- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ(១០ច្បាប់) លិខិតចូល(៣០ច្បាប់)
- ស្រង់វត្តមានប្រចាំថ្ងៃ ដើម្បីតាមដានការងារប្រចាំថ្ងៃរបស់មន្ត្រី ។
- ធ្វើរបាយការណ៍ប្រចាំសប្តាហ៍ និងខែ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។
- ធ្វើកំណត់ហេតុនៅរៀងរាល់កិច្ចប្រជុំ ។
- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា ។
- ប្រមូលរបាយការណ៍តាមបណ្តាអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥ ។
- បញ្ចប់បូកសរុបរបាយការណ៍ខែមិថុនា ឆ្នាំ២០១៧ របស់គ.ជ.ប.ជ ។
- រៀបចំធ្វើព្រឹត្តបត្តិព័ត៌មាន និងខិតប័ណ្ណផ្សព្វផ្សាយ ។
- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណសារវិតី ។
- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ។
- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយនៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា ។

### ២. ក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់

- ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧ លោកវរសេនីយ៍ឯក កែវ សុវណ្ណារ៉ា ប្រធានក្រុមជំនួយកិច្ចការបានអមដំណើរ **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍**គ.ជ.ប.ជ ចូលរួមសិក្ខាសាលា ស្តីពីកិច្ចសហការដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម នៅខេត្តកោះកុង ។
- ស្រង់ព័ត៌មានតាមរយៈតេឡេក្រាម នូវរាល់សកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានចុះផ្សព្វផ្សាយពីការបង្ការទប់ស្កាត់នៃភាពងាយរងគ្រោះ និងបទដ្ឋានច្បាប់នានាពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សនៅតាមសហគមន៍ សាលារៀន ដើម្បីជាបច្ច័យល្អដល់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

### ៣. ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ

- ថ្ងៃទី ២៦-២៨ ខែកក្កដា ឆ្នាំ២០១៧ បានរៀបចំបើកវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តកំពង់ស្ពឺ មានសិក្ខាកាមចូលរួមចំនួន ៦២នាក់ (ស្រី ១៣នាក់) ។

- តាមដានជនរងគ្រោះដែលបញ្ជូនមកពីក្រៅប្រទេស តាមរយៈក្រសួងការបរទេសៈ
  - ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានអន្តរាគមន៍ជួយដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍ពលករ-ពលការិនីខ្មែរចំនួន ១៦នាក់ ។
  - ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានអន្តរាគមន៍ជួយពលករ-ពលការិនីខ្មែរចំនួន ០៦នាក់ ។
  - ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ ប្រទេសថៃ បានស្វែងរកមេធាវីស្ម័គ្រចិត្តជួយការពារក្តី និងជម្រុញអាជ្ញាធរពាក់ព័ន្ធថៃ ពន្លឿនដំណើរការកាត់ក្តីពលករខ្មែរចំនួន ០៧នាក់ ។

## ៤. ក្រុមជំនួយកិច្ចការអនុវត្តច្បាប់

- តាមដាន និងប្រមូលទិន្នន័យលទ្ធផលបង្ក្រាបបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ។
- តាមដានសកម្មភាពការងារ និងប្រមូលរបាយការណ៍ ពាក់ព័ន្ធនឹងការងារអនុវត្តច្បាប់ នៅតាមបណ្តារាជធានី-ខេត្ត និងទំនាក់ទំនងសហការជាមួយក្រុមការងារអនុវត្តច្បាប់ ដែលដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ ។

## ៥. ក្រុមជំនួយកិច្ចការយុត្តិធម៌

- ថ្ងៃទី០៦-០៨ ខែកក្កដា ឆ្នាំ២០១៧ ឯកឧត្តមឧត្តមសេនីយ៍ឯក **យឹម វិរៈ** អគ្គលេខាធិការរង បានដឹកនាំក្រុមជំនួយកិច្ចការយុត្តិធម៌ ចុះបំពេញបេសកកម្មនៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីតាមដានការអនុវត្តវិធានការគ្រប់គ្រងលំហូរពលករចេញ-ចូល និងប្រមូលព័ត៌មានពីពលករដែលអាជ្ញាធរថៃចាប់បញ្ជូនមក ។
- ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ លោកឧត្តមសេនីយ៍ត្រី កែប សារឿន ប្រធានក្រុមជំនួយកិច្ចការ បានអញ្ជើញចូលរួមប្រជុំចង្អៀតដកបទពិសោធន៍ការងារ ស្តីពីការរៀបចំច្បាប់ការពពោះជំនួស ពីអ្នកជំនាញអន្តរជាតិរបស់អង្គការ UNICEF មកពីប្រទេសថៃ នៅទីស្តីការក្រសួងកិច្ចការនារី ។
- ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ បានចូលរួមធ្វើសន្និសិទសារព័ត៌មាន នៅសហភាពសហព័ន្ធអ្នកសារព័ត៌មានកម្ពុជា លើការផ្សាយព័ត៌មានរបស់បណ្តាញសារព័ត៌មាន CNN ។
- ទំនាក់ទំនង និងជម្រុញក្រុមការងារយុត្តិធម៌ ដើម្បីយកតួលេខជម្រះក្តីពីក្រសួងយុត្តិធម៌ ។

## ៦. ក្រុមជំនួយកិច្ចការទំនាក់ទំនងអន្តរជាតិ

- បានធ្វើការស្រាវជ្រាវឯកសារទាក់ទងនឹងអនុស្សរណៈយោគយល់គ្នា និងកិច្ចព្រមព្រៀងផ្សេងៗ ។
- រៀបចំ គ្រប់គ្រងបែបបទ និងតារាងព័ត៌មានដូចជាៈ ឈ្មោះអង្គការ ដៃគូអភិវឌ្ឍន៍ ច្រកចេញចូល និងប្រភេទពលករទេសន្តប្រវេសន៍ ។

## ៧. ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍

- ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៧ បានទំនាក់ទំនងតាមទូរស័ព្ទទៅប្រធានការិយាល័យច្រកទ្វារព្រំដែនអន្តរជាតិទូទាំងប្រទេស របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីយកព័ត៌មានអំពីស្ថានភាពជាក់ស្តែងរបស់ពលករទេសន្តប្រវេសន៍ខុសច្បាប់ដែលថៃចាប់បញ្ជូនត្រឡប់ ចាប់តាំងពីចុងខែមិថុនាមក ក្រោយពេលថៃអនុវត្តគោលការណ៍ទាំង៨ចំណុច ស្តីពីការគ្រប់គ្រងពលករទេសន្តប្រវេសន៍បរទេស ។

- ថ្ងៃទី០៦-០៨ ខែកក្កដា ឆ្នាំ២០១៧ ឯកឧត្តមឧត្តមសេនីយ៍ឯក ខៀវ ចាន់រ៉ា អគ្គលេខាធិការរង បានដឹកនាំក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ ចុះបំពេញបេសកកម្មនៅច្រកទ្វារព្រំដែនអន្តរជាតិដូង ខេត្តបាត់ដំបង ដើម្បីតាមដានការអនុវត្តវិធានការគ្រប់គ្រងលំហូរពលករចេញ-ចូល និងប្រមូលព័ត៌មានពីពលករដែលអាជ្ញាធរថៃចាប់បញ្ជូនមក ។
- បានបូកសរុបប្រចាំថ្ងៃនូវចំនួនពលករចំណាកស្រុកខុសច្បាប់ ដែលអាជ្ញាធរបរទេសបញ្ជូនមកកម្ពុជាវិញ(ពីថ្ងៃទី ០១-៣១ ខែកក្កដា ឆ្នាំ២០១៧) ដែលជារបាយការណ៍បូកសរុបប្រចាំថ្ងៃរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ មានចំនួនសរុប ៤.៣៩៦នាក់ (ស្រី ១.៦៣៨នាក់ កុមារ ៤៦៩នាក់) ក្នុងនោះ៖
    - តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ៣.៧៦០នាក់ (ស្រី ១.៣៩១នាក់ កុមារ ៤១៥នាក់)
    - តាមច្រកទ្វារអន្តរជាតិសំពៅលូន ៦៣៦នាក់ (ស្រី ២៤៧នាក់ កុមារ ៥៤នាក់) ។

## III. បញ្ហាប្រឈម និង សំណូមពរ

### ក. បញ្ហាប្រឈម

- ការផ្តល់របាយការណ៍ប្រចាំសប្តាហ៍និងខែ ពីបណ្តាអន្តរក្រសួង រាជធានី-ខេត្ត និងក្រុមមួយចំនួននៃអគ្គលេខាធិការដ្ឋាន មានការយឺតយ៉ាវ មិនទាន់ពេលកំណត់ ហើយរបាយការណ៍មិនទាន់មានទម្រង់ឯកភាពមួយត្រឹមត្រូវ ដែលជាហេតុនាំអោយមានភាពលំបាកក្នុងការបូកសរុប ។
- មន្ត្រីបំរើការងារនៅតាមការិយាល័យចំណុះឲ្យលេខាធិការដ្ឋានរដ្ឋបាលសរុប មានចំនួនតិច មិនទាន់ឆ្លើយតបទៅនឹងទំហំការងារ ។

### ខ. សំណូមពរ

- ស្នើសុំមន្ត្រីបន្ថែមដើម្បីជួយក្នុងការងារធ្វើកំណត់ហេតុប្រជុំ ។

## IV. ទិសដៅអនុវត្តបន្ត

- រៀបចំសិក្ខាសាលា ផ្សព្វផ្សាយផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៧-២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅទីស្តីការក្រសួងមហាផ្ទៃ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ ។
- រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាសមស្រប នៅតាមបណ្តាខេត្តគោលដៅជាបន្ត ។
- បន្តការសិក្សាស្វែងយល់អំពីការប្រែប្រួលលំហូរពលករទេសន្តរប្រវេសន៍ និងរៀបចំផែនការសកម្មភាពចុះសហការធ្វើការងារនេះបន្តទៀតជាមួយអង្គភាពពាក់ព័ន្ធនៅតាមព្រំដែន ។
- បន្តរៀបចំកម្មវិធីបណ្តុះបណ្តាលអំពីច្បាប់ សម្រាប់ចុះទៅបណ្តុះបណ្តាលនៅខេត្តស្ទឹងត្រែង ។
- បន្តទំនាក់ទំនង និងសហការជិតស្និទ្ធជាមួយក្រសួង-ស្ថាប័ន រាជធានី-ខេត្ត ដើម្បីតាមដាន ជំរុញ និងសម្របសម្រួលអំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- បន្តកសាងផែនការអប់រំ ផ្សព្វផ្សាយច្បាប់ គោលនយោបាយទាក់ទងនឹងច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដល់មូលដ្ឋានថ្នាក់ក្រោមជាតិ ។

- បន្តការស្រាវជ្រាវ និងប្រមូលប្រភេទឯកសារធ្វើដំណើរស្របច្បាប់របស់ពលករ ដែលអាចឆ្លងដែនទៅធ្វើការងារនៅប្រទេសថៃបាន និងនីតិវិធីក្នុងការបំពេញបែបបទ តាមរយៈក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីចងក្រងជាឯកសារ ។
- បន្តតាមដាន បូកសរុប និងស្រាវជ្រាវរកព័ត៌មានតាមរយៈតេឡេក្រាម និងគេហទំព័រផ្សេងៗពាក់ព័ន្ធដល់ពលករទេសន្តរប្រវេសន៍ ជនរងគ្រោះដែលបញ្ជូនមកពីក្រៅប្រទេស និងចំណាកស្រុកដែលឃាត់បាននៅតាមព្រំដែន ។
- បន្តពង្រឹងសមត្ថភាព និងវិន័យអោយកាន់តែល្អប្រសើរ ។
- ត្រៀមទទួលផែនការពីថ្នាក់ដឹកនាំ ។ល។ .

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៧

**ប្រធានលេខាធិការដ្ឋាន**

ឧត្តមសេនីយ៍ទោ. **គង់ - ពុទ្ធី**